**Program:** ឃាតកម្មមុនចូលគេង

**Topic:** Remy LECRENIER

(ពីការប្រច័ណ្ឌ ក្លាយជាឃាតកម្ម)

**Categories:** Crime Investigation

**Check: Done**

**Content by:** Prey Reung



---

៉៉

**Hook**

សូមស្វាគមន៏មកកាន់CamID Podcast!

កូនរបស់ខ្ញុំគួរតែស្លាប់ ” ពាក្យមួយឃ្លានេះ ពិតជាពិបាកឮចេញពីមាត់ម្តាយ របស់គេណាស់ ក៏ប៉ុន្តែ ដោយសារតែកូនប្រុសបង្កើតរបស់គាត់ ជាឃាតក ហ៊ានសម្លាប់មនុស្សដល់ទៅ ៤នាក់ ក្នុងរយះពេលតែមួយភ្លែតតែប៉ុណ្ណោះ ទើបគាត់ហ៊ាននិយាយបែបនេះ។

**Intro**

នេះគឺជាហេតុការណ៏មួយ ដែលកើតទៅលើគ្រួសាររបស់នារីម្នាក់ ដែលត្រូវសង្សាររបស់ឃាតក ដែលសម្លាប់នាង រួមទាំងបងប្អូនរបស់នាង ២នាក់ និងម្តាយរបស់នាង ថែមទៀតផង។ ដោយសារតែការប្រច័ន្ឋ ទើបធ្វើអោយរឿងដ៏រន្ធត់មួយនេះ កើតឡើងចំពោះគ្រួសារនាង។

រឿងដែលនឹកស្មានមិនដល់នោះគឺ បន្ទាប់ពីឃាតកសម្លាប់ពួកគេទាំងពីនាក់ នៅប៊ែលសិចហើយ បែរជាទៅដើរលេងនៅប្រទេសបារាំង ដោយគ្មានការសោកស្តាយអីបន្តិច។

សំណួរសួរថា តើដើមហេតុនៃរឿងនេះកើតមកពីអ្វី?

**Body**

រឿងរ៉ាវ កើតឡើងដោយសារបុរសម្នាក់ មានឈ្មោះថា Remy Lecrenier។

Remy កើតនៅក្នុងឆ្នាំ១៩៦៨ នៅក្នុងប្រទេសប៊ែលសិច។ ព្រៃរឿងសូមបញ្ជាក់ជាមុនផងដែរថា មិនមានប្រភពណា បង្ហាញពីជីវប្រវត្តរបស់គេឡើយ គ្រាន់តែដឹងថា គេគឺជាអ្នកចេះក្បាច់គុន ការ៉ាតេ យ៉ាងស្ទាត់ជំនាញ និងជាអ្នកដែលចូលចិត្ត ប្រើប្រាស់អាវុធ នៅពេលដែលមានបញ្ហាទៀតផង។ ហើយរឿងនេះគឺកើតឡើងនៅក្នុងឆ្នាំ១៩៩៧ ដោយពេលនោះគេមានអាយុ២៩ឆ្នាំ។

រឿងរ៉ាវ គឺបានមានការភ្ញាក់ផ្អើរក៏ដោយសារតែនៅ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៧ ដោយមាននារីម្នាក់ជាសង្សាររបស់Remyឈ្មោះ Vinciane Tellier អាយុ២៣ឆ្នាំ ដែលជានារីស្អាត ប្រចាំភូមិម្នាក់ត្រូវបានអ្នកភូមិប្រកាសថាស្លាប់។

មិនតែប៉ុណ្ណោះ ព័ណ៌មាននេះ ថែមទាំងបង្កការភ្ញាក់ផ្អើល ទៅដល់អ្នកជិតខាងទៀតផង ព្រោះនេះជាឃាតកម្មលក្ខណៈគ្រួសារ។

សំណួរសួរថា តើមានរឿងអ្វីកើតឡើងមុនពេលដែលនាងស្លាប់?

ឃាតកម្មនេះគឺមានការទាក់ទងទៅនឹង ស្នេហារវាងRemy និង Vincianeនោះឯង ពោលគឺមុនពេលដែលនាងស្លាប់ Vinciane បានបោះបង់ Remy ចោលកាលពីដើមរិសម្បកាលខែក្ដៅកន្លងផុតទៅ ដែលនេះ គឺជាលើកទីមួយ ក្នុងឆាកជីវិតរបស់គេដែលមាននារីបោះបង់គេចោលបែបនេះ ថ្វីបើគេជាមនុស្សប្រុសសង្ហាយ៉ាងណាក៏ដោយ។

គ្រានោះ Remy មានអារម្មណ៏ថា អាក់អន់ស្រពោនចិត្តខ្លាំងមែនទែន ដែលត្រូវសង្សារខ្លួនសូមបែកពីគេ។

គេក៏សម្រេចចិត្ត ចងគុំនំសងសឹក ទៅលើនាង និងគ្រួសារ ដើម្បីជាថ្នូរក្នុងការដោះដូរជាមួយកំហឹងរបស់គេ ពីព្រោះថានៅក្នុងក្រសែភ្នែករបស់គេ គេឃើញថាការបែកបាក់ដែលមកពីកំហុសរបស់Vinciane សឹងតែទាំងអស់។

នៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៧ ពោលគឺ មុនពេលដែល Vinciane ស្លាប់មួយថ្ងៃ គឺ Remy បានទៅលេងម្ដាយបង្កើតរបស់ខ្លួន នៅឯក្រុងWanze ដោយកុហកគាត់ថាមកយកខោអាវទៅរស់នៅជាមួយសង្សាររបស់គេគឺ Vinciane នោះឯង។

គ្រានោះ Remy ព្យាយាមធ្វើទឹកមុខធម្មតា ដើម្បីកុំអោយម្តាយបង្កើតរបស់គេដឹងថា គេមានគម្រោងសម្លាប់Vinciane។

យ៉ាងណា
ទឹកមុខរបស់គេនៅតែធ្វើអោយម្តាយរបស់គេនៅតែមានភាពងើយឆ្ងល់តែម្តាយរបស់គេមិនបានសួរនាំអ្វីឡើយ។

ក្រៅពីនេះគេថែមទាំងសារភាពទៅកាន់អ្នកកាសែតថា គេចង់សម្លាប់ទាំងឪពុករបស់Vincianeទៀតផង តែសំណាងល្អ ដោយសារនៅថ្ងៃកើតហេតុនោះ ឪពុករបស់នាង កំពុងនៅឯប្រទេសSpain។

សំណួរសួរថា តើហេតុការណ៍បានកើតឡើងយ៉ាងដូចម្តេច?

តួយ៉ាង នៅតាមផ្លូវត្រលប់ទៅ Bas-Oha វិញ ពួកគេបានចូលទៅទទួលទានភីហ្សាមួយ នៅឯ Aldo Paternico ដែលជាភោជនីយដ្ឋាន ដែលពួកគេធ្លាប់ទទួលទានអាហារពេលល្ងាច រ៉ូមែនទិកម្តង ក្នុងមួយសប្តាហ៍។

នៅពេលពួកគេមកដល់ផ្ទះរបស់Vinciane Remyបានសំលាប់នាងភ្លាមៗ ដោយបាញ់សម្លាប់ចំកញ្ចឹងក។

បន្ទាប់មក គាត់បានដាក់នាងនៅលើគ្រែ ហើយក៏បានយកធ្នូ
មកបាញ់ចំត្រង់ចំណុចបេះដូងរបស់នាងតែម្តង ដែលធ្នូរនោះ គាត់បានទិញនៅថ្ងៃតែមួយ នៅហាងលក់កាំភ្លើងក្បែរនោះ។

អាចនិយាយបានថា គេធ្វើបែបនេះប្រៀបដូចទៅនឹងរូបគំនូរធ្នូរ
បាញ់បេះដូងនោះឯង។ក្រោយពេលកើតហេតុ
គេបានរកឃើញភីហ្សាមួយចំនួនដែលនៅសេសសល់នៅផ្ទះរបស់ Vinciane

ដែលភីហ្សានោះត្រូវបានខាំតែមួយម៉ាត់ប៉ុណ្ណោះ ។មានន័យថាកំពុងតែបរិភោគភីហ្សាគឺRemyចាប់ផ្តើមធ្វើសកម្មភាពសម្លាប់នាង ។

នៅពេលព្រឹកប្រលឹម បន្ទាប់ពីគេបានបាញ់សម្លាប់ សង្សាររបស់ខ្លួនហើយ Remy ក៏បានចូលទៅក្នុងបន្ទប់របស់ប្អូនស្រីរបស់Vinciane ដែលម្នាក់ឈ្មោះថា Laurence និងម្នាក់ទៀតឈ្មោះថាVannesa ។

ស្របពេលដែលពួកគេទាំងពីរ កំពុងដេកលក់ ស្រាប់តែ Remyបានដកកាំភ្លើង បាញ់សម្លាប់ពួកគេតែម្តង ក៏ប៉ុន្តែ មុនពេលដែលគេសម្លាប់ គឺគេក៏បានបំពាន ទៅលើVannesaផងដែរ ។

Remy បានដឹងមុនហើយថា ម្តាយរបស់Vinciane ឈ្មោះGenevieve ដែលអាយុ៥០ នឹងត្រឡប់មកផ្ទះវិញ នៅរសៀលនឹង ។

ដូច្នេះ គេក៏រង់ចាំសម្លាប់ម្តាយរបស់Vincianeម្នាក់ទៀត ។

ពេលគឺ នៅពេលដែលម្តាយរបស់នាង បានត្រឡប់មកផ្ទះ Remy ក៏បានសម្លាប់ម្តាយរបស់នាងភ្លាម នៅក្នុងហ្គារ៉ាសតែម្តង ហើយថែមទាំងជូតដានឈាម ដែលជាប់នៅលើឥតថែមទៀត ។

នៅក្នុងចង្ក្រានបាយ មានពាក្យមួយឃ្លា ដែលRemyសរសេរថា កូនស្រីរបស់អ្នក អាចធ្វើអោយខ្ញុំទៅជាមនុស្សបាត់បង់សតិ ដែលពាក្យឃ្លានេះ ចង់បង្ហាញពីមូលហេតុដែលគេសម្លាប់Vinciane ។

បន្ទាប់ពីឃាតកម្មភ្លាម Remy ក៏បានរត់គេច ទៅកាន់ភាគខាងត្បូងនៃប្រទេសបារាំង រួចក៏ចំណាយពេលរបស់គេ សម្រាប់ថ្ងៃឈប់សម្រាក នៅកន្លែងបោះជំរុំមួយ ។

គេមិនបានខ្វាល់ខ្វល់ និងកើតទុក ចំពោះទង្វើដែលគេធ្វើនោះទេ ។

ផ្ទុយទៅវិញ គេបែរជារីករាយ នឹងអាកាសធាតុដ៏ស្រស់ស្អាត និងស្រីៗវ័យក្មេងនៅទីនោះទៅវិញ។ គេមានសភាពធម្មតា ប្រៀបដូចជាគ្មានរឿងអីកើតឡើងទាល់តែសោះ។

លើកលែងតែពេលដែលគេឃើញឡាន ដែលមានស្លាកលេខប្រទេសបែលហ្ស៊ិក ទើបគេងាកក្បាលចេញ ព្រោះធ្វើអោយគេនឹកដល់ហេតុការណ៏ដែលគេបានប្រព្រឹត្តនោះ។ម្យ៉ាងវិញទៀត ដោយសារតែគេ ដឹងថា នៅក្នុងប្រទេសប៊ែលហ្សិក ប្រាកដជាមានរូបថតរបស់គេ
មាននៅក្នុងគ្រប់សារព័ត៌មាននិងទូរទស្សន៍ហើយ។ដូច្នេះគេមិនចង់ទៅវិញនោះឡើយ។

មួយសប្តាហ៍ក្រោយមក Remy ត្រូវបានគ្រួសារ នៅប្រទេសប៊ែលហ្សិកមួយ ដែលនៅប្រទេសបារាំង បានស្គាល់មុខរបស់គេ បន្ទាប់ពីគេបានព្យាយាមលួងលោម និងញ៉ែញ៉ង់កូនស្រីរបស់ពួកគេ។ ហើយ គ្រួសារនោះក៏បានខលហៅប៉ូលីស។

មិនយូរមិនឆាប់ ការចាប់ខ្លួនRemyក៏បានមកដល់។

ក្រុមប៉ូលិសបារាំង ក៏បានបន្លំខ្លួនជាអ្នកបោះតង់ នៅឯជំរំដែលRemyបានបោះតង់នៅទីនោះ។

ម្តងនេះRemy គ្មានឱកាសរត់គេចពីឃ្នោះរបស់ប៉ូលិសបាននោះទេ។ ហើយគេ ក៏ត្រូវបានចាប់ខ្លួន ហើយថ្ងៃបន្ទាប់ គេក៏ត្រូវបញ្ជូនទៅកាន់ ប្រទេសប៊ែលសិកវិញ។

ចុងក្រោយនៅឆ្នាំ១៩៩៩ គេត្រូវបានតុលាកាត់ទោស អោយជាប់ពន្ធធនាគារអស់មួយជីវិត ក៏ប៉ុន្តែសម្បីតែនៅក្នុងគុកក៏ដោយ គេនៅតែប្រព្រឹត្តអំពើព្រៃផ្សៃបានដដែរ ព្រោះថា នៅក្នុងពន្ធធនាគារនោះ គេបានបំពានអ្នកទោសស្រ្តី ដល់ទៅ៥នាក់ឯនោះ។

**Ending:**

តាមរយៈរឿងរ៉ាវនេះ យើងអាចស្វែងយល់បានថា

ស្នេហាគឺជារឿងដ៏ស្រស់ស្អាត តែមនុស្សទៅវិញទេ ដែលតែងតែធ្វើឲ្យរឿងដ៏ស្រស់ស្អាតនេះ ទៅជារឿងល្អក់កករ។

ការបែបបាក់ស្នេហា គឺជារឿងដែលមនុស្សគួរស្វែងយល់ដើម្បីស្វែងរកបញ្ហាដែលបានកើតឡើង ដើម្បីជាមេរៀនក្នុងឆាកជីវិត ដោយមិនមែនបង្កើតជាគំនុំសងសឹកក្នុងរូបភាពណាក៏ដោយនោះទេ ដែលវានឹងអាចធ្វើឲ្យអ្នកបាត់បង់ភាពជាមនុស្សជាតិក្នុងកំរឹតណាមួយ។

ម្យ៉ាងវិញទៀត ស្នេហាគឺជាការផ្តល់ឲ្យ នោះបានន័យថា ក្តីស្រលាញ់ ការយោគយល់ និងទឹកចិត្ត គឺជាអ្វីដែលគូស្នេហ៍គួរតែផ្តល់ឲ្យគ្នាទៅវិញទៅមក ទោះបីជាដៃគូម្នាក់ទៀត ធ្វើអំពើមិនគប្បីដែលឈានទៅដល់ការបែបបាក់ក៏ដោយ យើងគួរតែយោគយល់ និងរាប់ទុកជាមេរៀន ព្រោះមនុស្សម្នាក់ មិនអាចបង្ខំឲ្យមនុស្សម្នាក់ទៀត នៅជាមួយយើងមួយជីវិតនោះទេ។

សូមស្តាប់ ដោយត្រិះរិះពិចារណា។

សម្រាប់ពេលនេះ សុបិនល្អ និងរាត្រីសួស្តី។

Links and Resources

https://www.nieuwsblad.be/
https://www.rtbf.be/
https://www.lalibre.be/
https://murderpedia.org/